# **សុន្ទរកថា**
# **ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី**
# **ទទួលបន្ទុកដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**
# **និងជាទីប្រឹក្សាជាន់ខ្ពស់សមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា**
# **ក្នុងឱកាសបើកសន្និសីទគរុសភាស្តីពី**
# **មិត្តភាព៥០០ឆ្នាំ ៖ ព្រះសហគមន៍គ្រិស្តសាសនា និងព្រះរាជាណាចក្រកម្ពុជា**

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣

- *សូមក្រាបថ្វាយបង្គំព្រះមុនីកោសលបណ្ឌិត ព្រះតេជគុណ យ៉ន សេងយៀត សាកលវិទ្យាធិការស្តីទីនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ*
- *H.E. Monsignor Olivier Schmitthausler, Apostolic Vicar of Phnom Penh*
- *ឯកឧត្តមបណ្ឌិតសភាចារ្យ ស៊ន សំណាង ទីប្រឹក្សារាជរដ្ឋាភិបាល និងជាប្រធានសមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា*
- *ឯកឧត្តម សាន វឌ្ឍនា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា*
- *ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ជាវាគ្មិន និងអ្នកចូលរួមទាំងអស់*

សន្និសីទគរុសភាស្តីពី«មិត្តភាព៥០០ឆ្នាំ៖ ព្រះសហគមន៍គ្រិស្តសាសនា និងព្រះរាជាណាចក្រកម្ពុជា» ដែលកំពុងប្រព្រឹត្តទៅនៅថ្ងៃនេះ មានអត្ថន័យជាប្រវត្តិសាស្ត្រយ៉ាងធំធេង ពីព្រោះជា វេទិកាគរុសភាដ៏ប្រសើរមួយ ដើម្បីរំឭកឡើងវិញអំពីអនុស្សាវរីយ៍ជាមិត្តភាពរវាងបារាំង និងកម្ពុជា ក្នុងអំឡុង៥សតវត្សរ៍កន្លងទៅ។

ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះគណៈកម្មការរៀបចំសន្និសីទនេះ ដែលមានកិច្ចសហការរវាងថ្នាក់ដឹកនាំនៃស្ថាប័នចំនួន៣គឺ សមាគមបេសកជនបារាំង, សមាគមអ្នកប្រវត្តិសាស្ត្រកម្ពុជា និងដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ថ្នាក់ដឹកនាំនៃវិទ្យាស្ថានអប់រំអន្តរជាតិ (អ៊ីនធីរេដ) ក៏បានចូលរួមយ៉ាងសកម្ម ជាមួយស្ថាប័នទាំងបីនេះ ដែលអ្នករៀបចំ និងវាគ្មិនទាំងអស់សុទ្ធតែជាអ្នកស្ម័គ្រចិត្តមិនគិតកម្រៃ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ដែលអញ្ជើញមកចូលរួមក្នុងពិធីបើកសន្និសីទនេះ។

ខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេស ចំពោះឯកឧត្តម អ្នកឧកញ៉ា លោក លោកស្រី ជាវាគ្មិន ដែលជាសាស្ត្រាចារ្យប្រវត្តិវិទ្យាខ្មែរដ៏ឆ្នើមៗ ជាវរជនខ្មែរ និងជាវរជនអ្នកជំនាញខាងគ្រិស្តសាសនាបារាំង និងខ្មែរ ដែលនឹងចែករំលែកនូវចំណេះដឹង និងបទពិសោធន៍

អតីតកាលស្ដីពីប្រធានបទនេះ ដល់អ្នកចូលរួមនៅទីនេះនិងនៅជុំវិញពិភពលោក តាមរយៈប្រព័ន្ធនិមិត្ត (Online)។

ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមចូលរួមចែករំលែកនូវការយល់ឃើញមួយចំនួនលើទំនាក់ទំនងរវាងព្រះសហគមន៍គ្រិស្ដសាសនា និងព្រះរាជាណាចក្រកម្ពុជា ដូចតទៅ ៖

ឆ្នាំ១៥១៥ អាចចាត់ទុកជាឆ្នាំគោលសំខាន់មួយ នៃការចាប់ផ្ដើមវត្តមានគ្រិស្ដសាសនានៅព្រះរាជាណាចក្រកម្ពុជា។ ប្រភពឯកសារមានចំណាស់ជាងគេដែលសរសេរអំពីប្រវត្តិនេះ គឺសៀវភៅមានចំណងជើងថា៖ «ការរុករកនិងបេសកកម្មរបស់លោកឌូដា ដឺឡាគ្រេ» ឆ្នាំ១៨៨៣ (Explorations et missions de Doudart de Lagrée, 1883) ដែលបានឱ្យយើងដឹងថា នៅឆ្នាំ១៥៥៣ បេសកជនកាតូលិកដំបូងៗ ដែលបានមកដល់ប្រទេសកម្ពុជានោះ គឺជនជាតិព័រទុយហ្គាល់ឈ្មោះ Louis Cardoso និង Jean Madeira។

លោកឌូដា ដឺឡាគ្រេ ដែលជាអ្នកតំណាងរបបអាណាព្យាបាលបារាំងទី១ប្រចាំនៅកម្ពុជានោះ បានឱ្យដឹងទៀតថា ព័ត៌មានស្ដីពីបេសកកម្មកាតូលិកនៅកម្ពុជា បានមកពី «បណ្ណសារនៅពញាឮ» (Archives de Ponhea Lu) ជាបុរីកាតូលិកដែលព្រះសង្ឃរាជមីស (Monseigneur Miche) គង់នៅ ហើយចាប់ពីពាក់កណ្ដាលសតវត្សរ៍ទី១៧មក បេសកកម្មកាតូលិកបារាំង ជាបេសកកម្មសំខាន់ជាងគេ។

តាមសៀវភៅរបស់លោក François Ponchaud ដែលមានចំណងជើងថា «វិសាលវិហារនៅស្រុកស្រែ» (La Cathédrale de la rizière, 1990) នោះ នៅឆ្នាំ១៥៥៥ ព្រះបាទអង្គច័ន្ទបានឃើញជនបរទេសម្នាក់ឈ្មោះ Gaspar da Cruz ជាជនជាតិព័រទុយហ្គាល់ មកដល់រាជវាំងលង្វែក។ គ្រិស្ដសាសនិកនេះ មកពីម៉ាឡាកា និងឡើងគោកនៅពាម គឺហាទៀងសព្វថ្ងៃនេះ។ លោកPonchaud បានផ្ដល់តម្លៃខ្ពស់ចំពោះប្រទេសកម្ពុជា ដែលជា «ទីជម្រករបស់ពួកអ្នករងគ្រោះពីការធ្វើទុកបុកម្នេញខាងសាសនា» (Cambodge, terre d'asile des persécutés)។

ក្នុងអំឡុង៥សតវត្សរ៍នៃ «មិត្តភាពរវាងព្រះសហគមន៍គ្រិស្ដសាសនា និងព្រះរាជាណាចក្រកម្ពុជា»នេះ មានបទពិសោធន៍ និងមេរៀនអតីតកាលល្អៗជាច្រើនសម្រាប់ប្រជាជាតិទាំងពីរគឺបារាំង និងកម្ពុជា។ ខ្ញុំសូមលើកយកចំណុចសំខាន់មួយចំនួន មកពិចារណាដូចខាងក្រោមនេះ ៖

## ១-បេសកកម្មអរិយធម៌របស់បព្វជិតកាតូលិកបារាំងនៅកម្ពុជា

ក្នុងអំឡុងពេលនៃការពង្រីកអាណានិគមនៃទ្វីបអឺរ៉ុបរវាងសតវត្សទី១៥ និងទី២០នោះ បេសកកម្មអរិយធម៌ (Mission civilisatrice) គឺជាទ្រឹស្ដីមួយ ដែលត្រូវបានបង្កើតឡើង

នៅក្នុងប្រទេសបារាំង និងនៅក្នុងបណ្តាប្រទេសនៅអឺរ៉ុប ដែលចាត់ទុកថាជាប្រទេសដែលមានអរិយធម៌ខ្ពង់ខ្ពស់ ហើយមានបេសកកម្មផ្តល់នូវ "អរិយធម៌" ដល់ប្រជាជនមិនមែនអឺរ៉ុប-មិនមែនគ្រិស្តសាសនិក។

ជាការអនុវត្តតាមទ្រឹស្តីនេះជនជាតិបារាំងដែលជាបេសកជនកាតូលិកបានផ្សព្វផ្សាយអរិយធម៌នៅប្រទេសកម្ពុជា ជាពិសេសក្នុងសតវត្សរ៍ទី១៩។ នៅក្នុងសៀវភៅដែលមានចំណងជើងថា៖ «ការធ្វើដំណើរក្នុងព្រះរាជាណាចក្រសៀម, កម្ពុជា និងឡាវ» ឆ្នាំ១៨៥៨-៦១នោះ លោកហង់រី មូហូត៍ (Henri Mouhot) បានឱ្យដឹងអំពីការតស៊ូរស់នៅយ៉ាងលំបាករបស់បេសកជនកាតូលិកបារាំងដូចជា លោក Cordier ជាអ្នកត្រួសត្រាយផ្លូវនៃអរិយធម៌ម្នាក់ប្រចាំនៅកោះសុទិន ដែលកើតជំងឺរុំរ៉ៃអស់រយៈពេលបីឆ្នាំមកហើយ (Mouhot ទំព័រ ១៩៥-៩៦)។

ប៉ុន្តែ នៅឯបុរីពញាឮជាកន្លែងស្នាក់នៅរបស់សង្ឃរាជកាតូលិកបារាំងមួយរូបគឺសម្តេចមីស (Monseigneur Miche) មានអ្នកផ្សព្វផ្សាយសាសនា៣នាក់ «មានសុខភាពល្អ និងពោរពេញទៅដោយភាពរីករាយ» ផ្ទុយពីពេលដែលលោកបានស្នាក់នៅឯកូសាំងស៊ីន និងនៅទីក្រុងបាងកក ដែលនៅពេលនោះ លោកមានសុខភាពទន់ខ្សោយ និងមានទុក្ខព្រួយផង។ (Mouhot ទំព័រ ១៣៧-១៣៨)។

នៅឯបុរីពញាឮ សម្តេចមីស (Monseigneur Miche) បានបំពេញតួនាទីយ៉ាងសំខាន់ជាអន្តរការីរវាងព្រះបាទអង្គដួង និងព្រះចៅអធិរាជបារាំង ណាប៉ូលេអុងទី៣។ ដោយសារទំនាក់ទំនងយ៉ាងល្អនេះ ព្រះបាទអង្គដួងបានជ្រើសរើសយក «ដំណោះស្រាយបារាំង» (Solution française) សម្រាប់ភាពគង់វង្សនៃព្រះរាជបល្ល័ង្ករបស់ព្រះអង្គ និងប្រជាជាតិកម្ពុជា។

គួររំឭកថា អត្ថបទនៃសារព័ត៌មានបារាំងនៅក្រុងព្រៃនគរ ចេញផ្សាយនៅក្នុងខែកញ្ញា ឆ្នាំ១៨៦៣ (Courrier de Saigon, septembre 1863) នោះបានបញ្ជាក់ថា៖ «...ឧត្តមនាវី La Grandière តាំងពីលោកបានកាន់កាប់រដ្ឋាភិបាលកូសាំងស៊ីនមក ដែលតែងតែបង្ហាញនូវសកម្មភាពឱ្យឃើញផលប្រយោជន៍ទាំងអស់នោះ ទើបតែបានចូលគាល់ព្រះមហាក្សត្រកម្ពុជា»។ នេះជាឱកាសដ៏ល្អសម្រាប់រំឭកថា កម្ពុជាជាប្រទេសតែមួយគត់នៅចុងបូព៌ា ដែលមានការយោគយល់ចំពោះគ្រិស្តសាសនា។ សម្តេចសង្ឃកាតូលិកមីស ធានាថាគ្មានអ្វីត្រូវត្អូញត្អែរអំពីការប្រព្រឹត្តរបស់មន្ត្រីនានាដែលគ្រប់គ្រងដែនដីថ្នាក់ខេត្តស្រុកនោះទេ។ (Mouhot ទំព័រ២១២)

## ២-អរិយធម៌ខ្ពស់របស់ខ្មែរដែលបារាំងកោតសរសើរ

លោកមូហូត៍ (Mouhot) បានសរសេរថា ៖ នៅពេលឃើញប្រាសាទនេះភ្លាម

(ប្រាសាទអង្គរវត្ត) យើងវង្វេងបាត់ស្មារតី មានការស្រមើលស្រមៃហួសនិស្ស័យ យើងសម្លឹងមើល យើងកោតសរសើរ ហើយដោយក្តីគោរព យើងនៅស្ងៀមលែងស្រដី ពីព្រោះមិនអាចរកពាក្យណាឱ្យសក្តិសម ដើម្បីស្ញើចសរសើរចំពោះស្នាដៃស្ថាបត្យកម្មមួយ ដែលប្រហែលជាមិនមាន ដែលប្រហែលជាគ្មានពីរ នៅលើភពផែនដីនេះ។ (Mouhot ទំព័រ១៩៤)

## ៣-បេសកកម្មអរិយធម៌របស់អ្នករដ្ឋបាលបារាំងនៅកម្ពុជា

លោក ឌូដា ដឺឡាគ្រេ ដែលជាអ្នកតំណាងរបបអាណាព្យាបាលបារាំងទី១ប្រចាំនៅកម្ពុជានោះ នៅក្នុងសៀវភៅមានចំណងជើងថា៖ «ការរុករកនិងបេសកកម្មរបស់លោកឌូដា ដឺឡាគ្រេ» ឆ្នាំ១៨៨៣ (Explorations et missions de Doudart de Lagrée, 1883) បានបង្ហាញឱ្យឃើញនូវការខិតខំសរសេរចងក្រងអំពីប្រវត្តិសាស្ត្រកម្ពុជា ព្រមទាំងបង្កើតមុខជំនាញបុរាណវិទ្យា និងសិលាចារឹកវិទ្យា ដើម្បីបើកផ្លូវឱ្យមានការស្រាវជ្រាវអំពីអតីតកាលនៃប្រទេសកម្ពុជាយ៉ាងទូលំទូលាយជាបន្តមក។

បន្ទាប់មក លោក ហ្សង់ មូរ៉ា និងលោក អាយម៉ូនីញេ៉ ដែលសុទ្ធតែជាអ្នកតំណាងរបបអាណាព្យាបាលបារាំង បានផ្តល់ជាគំរូយ៉ាងល្អសម្រាប់បារាំង និងខ្មែរ ឱ្យខិតខំស្រាវជ្រាវ និងចងក្រងឯកសារអំពីប្រវត្តិសាស្ត្រ វប្បធម៌ និងអរិយធម៌ខ្មែរ ដើម្បីពង្រឹងជំហរជាតិខ្មែរឡើងវិញ ក្រោយពីបានធ្លាក់ចុះជាច្រើនសតវត្សរ៍ មុនពេលបារាំងមកដល់។

លោកជាអ្នកតំណាងរបបអាណាព្យាបាលបារាំងទាំងបីនេះ ពិតជាបានបំពេញបេសកកម្មអរិយធម៌ដ៏ប្រសើរនៅក្នុងប្រទេកម្ពុជា នាចុងសតវត្សរ៍ទី១៩នោះ។

## ៤-ការបង្កើតស្ថាប័នអប់រំសាសនា និងវប្បធម៌ នៅសម័យបារាំង

ដោយមិនមានការប្រកាន់ជំនឿសាសនានោះ ពួកមន្ត្រីបារាំងបានខិតខំបង្កើតស្ថាប័នអប់រំពុទ្ធសាសនា និងវប្បធម៌ជាច្រើននៅកម្ពុជាដូចជា៖ សាលាបាលីនៅភ្នំពេញឆ្នាំ១៩១៤ ដែលក្លាយជាសាលាបាលីជាន់ខ្ពស់នៅឆ្នាំ១៩២២ និងពុទ្ធសាសនបណ្ឌិត្យនៅឆ្នាំ១៩៣០។

សរុបសេចក្តីមក មាននិក្ខេបបទខាងប្រវត្តិសាស្ត្រសំខាន់ពីរ ដែលបានបង្ហាញអំពីមិត្តភាពរវាងបារាំង និងកម្ពុជា ក្នុងសម័យអាណាព្យាបាលបារាំង។ សាស្ត្រាចារ្យ Alain Forest បានដាក់ចំណងជើងនៃនិក្ខេបបទរបស់លោកដែលមានពាក្យថា «ប្រវត្តិនៃអាណានិគមកម្មមួយដែលគ្មានការប៉ះទង្គិច»។ ចំណែកនិក្ខេបបទរបស់បណ្ឌិតសភាចារ្យ ស៊ិន សំណាងវិញ បានធ្វើសេចក្តីសន្និដ្ឋានថា «ក្នុងអំឡុងពេល៩០ឆ្នាំ បារាំងបានចែករំលែកជាមួយកម្ពុជានូវជោគវាសនារួម»។

សូមអរគុណ!